00649708

E211

**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 03 / 2011
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ |
| ដាក់ជូន៖ | **អង្គជំនុំជម្រះតុលាការកំពូល** |
| ភាសាដើម៖ | បារាំង (បកប្រែខ្មែរ) |
| កាលបរិច្ឆេទឯកសារ៖ | ០៤ មីនា ២០១១ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស៖ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ÷ ការស្នើសុំឲ្យទទួលយកនូវសំអាងគតិច្បាប់បន្ថែម ដើម្បីគាំពារសារណាបណ្តឹងឧទ្ធរណ៍**

---

**ដាក់ដោយ៖**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
មេធាវី ម៉ុច សុវណ្ណារី
មេធាវី គឹម ម៉េងឃី
មេធាវី Philippe CANONNE
មេធាវី Elizabeth RABESANDRATANA
មេធាវី Martine JACQUIN
មេធាវី Annie DELAHAIE
មេធាវី Fabienne TRUSSES-NAPROUS
មេធាវី Christine MARTINEAU

**ដាក់ជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម (ប្រធាន)
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម យ៉ា ណារិន
ចៅក្រម Motoo NOGUCHI
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម Chandra Nihal JAYASINGHE

**ចម្លងជូន៖**

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីការពារក្តីជនជាប់ចោទ**
មេធាវី ការ សាវុត្ថ

P2/1

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

លោក យ៉េត ចរិយា

លោក William SMITH

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវី នី ចាន់ឌី

មេធាវី គង់ ពិសី

មេធាវី ឡោ ជុនធី

មេធាវី ហុង គឹមសួន

មេធាវី Silke STUDZINSKY

មេធាវី Karim KHAN

មេធាវី Alain WERNER

I- **សេចក្តីផ្តើម**

1- នៅថ្ងៃទី២៦ កក្កដា ២០១០ អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.កបានប្រកាសថា កាំង ហ្កេកអ៊ាវ ជាពិរុទ្ធជននៃបទឧក្រិដ្ឋដែលរំលោភយ៉ាងធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងហ្សឺណែវ និង បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ព្រមទាំងបានផ្តន្ទាទោសដាក់ពន្ធនាគារ ៣៥ឆ្នាំ ។ រយៈពេលផ្តន្ទាទោសដាក់ពន្ធនាគារនេះត្រូវដកចេញចំនួន៥ឆ្នាំវិញ ដោយសារការឃុំខ្លួនដោយខុសច្បាប់បំពានលើពិរុទ្ធជនរូបនេះ។

2- នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍ដើម្បីជំទាស់នឹងសាលក្រម ដែលបានប្រកាសថាមិនទទួលយកដោយគ្មានមូលដ្ឋាននូវការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលតំណាងដោយក្រុមមេធាវីខាងលើ និង លើបញ្ហាសំណង។

3- ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១០ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់នូវការសង្កេត បន្ទាប់ពីបណ្តឹងឧទ្ធរណ៍របស់ភាគីការពារក្តី នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

4- តាមរយៈអនុស្សារណៈចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ និងយោងតាមកថាខណ្ឌ១០៦នៃសារណាឧទ្ធរណ៍របស់សហមេធាវីក្រុម៣ សហមេធាវីក្រុមបីបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលទទួលយកនូវការដាក់ឯកសារបន្ថែម ។ ស្របតាមវិធាន១០៨(៧)នៃវិធានផ្ទៃក្នុងសើរើលើកទី៦ ក្រលាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល បានស្នើសហមេធាវីក្រុមបីឲ្យដាក់នូវការសុំឲ្យទទួលយកនូវភស្តុតាងបន្ថែម ។

5- អនុស្សារណៈនេះបានស្នើឲ្យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់ការសុំនេះជាភាសាខ្មែរនិងភាសាបារាំង ឲ្យបានត្រឹមថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ ។

6- ដូច្នេះការស្នើសុំនេះអាចទទួលយកបាន ។

II- **ការពិភាក្សា**

7- ដោយយោងវិធាន១០៨នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៦) «ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជ្រះតុលាការកំពូល យោងតាមវិធាន ៨៧ (៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចក្នុងសវនាការ។ សេចក្តីសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុបញ្ជាក់ជាក់លាក់ ដែលអង្គជំនុំជម្រះសា

លាដំបូងបានលើក។ ភាគីផ្សេងទៀតដែលបានរកការប៉ះពាល់ ដោយសេចក្តីស្នើសុំនេះ អាចធ្វើការឆ្លើយតបក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃទទួលបានការជូន ដំណឹងអំពីសេចក្តីស្នើសុំនោះ»។

8- ដោយយោងវិធាន៨៧ (៣) នៃវិធានផ្ទៃក្នុង «អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំនុំរឿងប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬ អង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំនុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬ ភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬ ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របក្នុងសាវនាការ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖

ក. មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា

ខ. មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ. មិនអាចសមស្របសំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ. ច្បាប់មិនអនុញ្ញាត ឬ

ង. មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍ »

## A. សំអាងនៃភស្តុតាងបន្ថែមសម្រាប់គាំពារការស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក អោគ ខន

9- លោក អោគ ខន (E2/33) ត្រូវបានធ្វើទារុណកម្ម និងសួរចម្លើយនៅក្នុងពន្ធនាគារមួយដែលស្ថិតនៅទីក្រុងភ្នំពេញក្នុងអំឡុងពេលសម័យកម្ពុជាប្រជាធិបតេយ្យ ។

10-ដើម្បីបដិសេធការស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកសំអាងថា ៖ *«ទោះបីជាអង្គជំនុំជម្រះយល់ថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអាចត្រូវបានទាហានខ្មែរក្រហមឃុំខ្លួន និងធ្វើទារុណកម្មក្តី ក៏មិនមានភស្តុតាងពិតប្រាកដបង្ហាញថាការឃុំខ្លួន និងការធ្វើទារុណកម្មកើតឡើងនៅមន្ទីរស២១ដែរ»* ។

00649712



F2/1

11-លោក ភោគ ខន(E2/33) ក៏បានបញ្ជាក់ផងដែរថា សមាជិកគ្រួសាររបស់គាត់ក៏បានស្លាប់នូវមន្ទីរ ស២១។ គឺបន្ទាប់ពីការស្វែងរកនៅមន្ទីរសន្តិសុខនេះ ទើបគាត់អាចចំណាំនូវរូបភាពប្រពន្ធគាត់[1] រូបភាពឪពុកមាគាត់[2] និងរូបភាពប្រពន្ធឪពុកមាគាត់[3]។

12-រូបភាពទាំងនេះត្រូវបានដាក់ភ្ជាប់ដើម្បីគាំពារការស្នើសុំនេះ ។

## B. សំអាងនៃភស្តុតាងបន្ថែមសម្រាប់គាំពារការស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ឡាយ ចាន់

13-ករណីលោក ឡាយ ចាន់(E2/23) អង្គជំនុំជម្រះសាលាដំបូងបានលើកថា *«ទោះបីជាអង្គជំនុំជម្រះមិនមានការសង្ស័យថា ឡាយ ចាន់ (E2/23) ទទួលរងការខូចខាតយ៉ាងខ្លាំងដោយសារតែ ការឃុំខ្លួន ការសួរចម្លើយ និងការធ្វើទារុណកម្មក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មិនមានភស្តុតាង បង្ហាញថាការខូចខាតនេះកើតឡើងនៅមន្ទីរស២១ទេ»* ។

14-*អង្គជំនុំជម្រះបន្តទៀតថា «ទោះបីជាអង្គជំនុំជម្រះមិនមានការសង្ស័យថា ឡាយ ចាន់ (E2/23) ទទួលរងការខូចខាតយ៉ាងខ្លាំងដោយសារតែ ការឃុំខ្លួន ការសួរចម្លើយ និងការធ្វើទារុណកម្មក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យក៏ដោយ ។ ប៉ុន្តែការរៀបរាប់អំពីស្ថានភាពឃុំខ្លួននេះ មិនស៊ីសង្វាក់គ្នាជាមួយនឹងភស្តុតាងជាច្រើនដែលដាក់ជូនអង្គជំនុំជម្រះទាក់ទងនឹងប្រតិបត្តិការនៅមន្ទីរស២១។ »*

15-ជាពិសេស *«គាត់បានរៀបរាប់អំពីបន្ទប់ឃុំឃាំងគាត់ដែលមិនស៊ីសង្វាក់គ្នានឹងអ្នកផ្សេងទៀតដែលរៀបរាប់អំពីបន្ទប់ឃុំឃាំងនៅមន្ទីរស២១ [...]»*

16-ផ្ទុយមកវិញ រូបថតថតនៅមន្ទីរស២១ បានបង្ហាញដូចអ្វីដែលលោកឡាយចាន់បាននិយាយរៀបរាប់ និងអះអាងជាច្រើនលើកច្រើនសារមែន[4] ថាពិតជាមានបន្ទប់ឃុំឃាំងស្ថិតនៅក្រោមជណ្តើរ ។

## III- សន្និដ្ឋាន

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចទទួលយកនូវសំអាងភស្តុតាងបន្ថែមនេះ ។

---

[1] ឧបសម្ព័ន្ធ១និង២៖ រូបថតប្រពន្ធលោកភោគខន

[2] ឧបសម្ព័ន្ធ៣និង៤៖ រូបថតឪពុកមាលោកភោគខន

[3] ឧបសម្ព័ន្ធ៥និង៦៖ រូបថតមីងលោកភោគខន

[4] រូបថតថតនៅមន្ទីរស២១ដែលជាបន្ទប់ឃុំឃាំងលោកឡាយចាន់

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១១

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣

<u>មេធាវី គឹម ម៉េងឃី</u> <u>មេធាវី Martine JACQUIN</u>

Me Martine JACQUIN
Chef de projet ASF-France

មេធាវី ម៉ុច សុវណ្ណារី

មេធាវី Philippe CANONNE

មេធាវី Christine MARTINEAU

មេធាវី Fabienne TRUSSES-NAPROUS

មេធាវី Annie DELAHAIE

មេធាវី Elisabeth RABESANDRATANA